# រាត្រីនឹកអូន

ពាក្យ៨

គេងគិតចិត្តតឹងមិនដឹងហេតុអ្វី
ពេញមួយរាត្រីស្រីនៅនេបនិត្យ
ច័ន្ទរះសែនឆ្ងាយតែមានអូនជិត
ធ្វើឲ្យជីវិតមានសុខក្លឹមសារ។
ច័ន្ទរះនៅទាបតែចាប់មិនបាន
រះទាបជាងប្រាណតែប្រុសរៀមវ៉ា
ឈោងមិនដល់សោះម្ល៉ោះច័ន្ទជីវ៉ា
អូនរះនេះណាជាស្រមោលថ្លៃ។
រូបស្ងួននួនពិតវមិត្ររះខ្ពស់
ឆ្ងាយអើយឆ្ងាយហួសលើសលោះនិស្ស័យ
មិនអាចលូកក្បែរអង្អែលដោយដៃ
មានតែស្រម៉ៃទើបប៉ះច័ន្ទបាន។
គេងគិតគេងកើយខ្នើមវិលចុះឡើង
មួលហ្មងសើងម៉ើងចុកឈឺឥតស្រាន្ត
ធ្វើម្តេចបាននៅជិតពៅកល្យាណ
សាងស្នេហ៍សុខសាន្តជាមួយច័ន្ទថ្លៃ។
នឹកអើយនឹកស្រីគ្មានអ្វីជួសសោះ
គ្រប់យ៉ាងភ្លេចអស់នៅតែចរណៃ
នឹកព្រឹករសៀលនឹកយប់នឹកថ្ងៃ
នឹកស្រស់ឆ្នើមឆ្នៃពេញរាល់រាត្រី។

ភ្នំពេញ ១៣ កក្កដា ២០០៥

សួយ ឡូត